# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៥៦២ **អយក.សជណ**

# សេចក្តីជូនដំណឹង
## ស្តីពីការជ្រើសរើសនិស្សិតអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិតក្រោមគម្រោងអាហារូបករណ៍របស់ប្រទេសជប៉ុនសម្រាប់ការអភិវឌ្ឍធនធានមនុស្សនៅប្រទេសកម្ពុជាក្នុងឆ្នាំ២០២១

យោង: លិខិតចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២០ របស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន JICE។

ក្រសួងអប់រំ យុវជន និងកីឡា សូមជូនដំណឹងថា៖ សម្រាប់ឆ្នាំសិក្សា២០២១-២០២២នេះ កម្មវិធីអាហារូបករណ៍ជប៉ុនJDS ក្រោមជំនួយរបស់រដ្ឋាភិបាលជប៉ុនសម្រាប់ការអភិវឌ្ឍធនធានមនុស្សនៅកម្ពុជានឹងទទួលបណ្តុះបណ្តាលមន្ត្រីរាជការ អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ (Master's Degree) រយៈពេល ២ ឆ្នាំ ចំនួន**២៤នាក់** និងថ្នាក់បណ្ឌិត (Ph.D Degree) រយៈពេល ០៣ឆ្នាំ ចំនួន **០២នាក់** នៅប្រទេសជប៉ុនក្នុងឆ្នាំ២០២១។

មធ្យោបាយធ្វើដំណើរទៅមក កម្ពុជា/ជប៉ុន/កម្ពុជា ថ្លៃសិក្សា ប្រាក់អាហារូបករណ៍ជាបន្ទុករបស់រដ្ឋាភិបាលជប៉ុន។

**I - លក្ខខណ្ឌនៃការជ្រើសរើស**

**១. ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ (Master)**

**បេក្ខជនទាំងពីរភេទត្រូវ៖**

- មានសញ្ជាតិខ្មែរ
- មានសញ្ញាបត្របរិញ្ញាបត្រ (Bachelor's Degree)
- មានអាយុចន្លោះពី **២២-៣៩ឆ្នាំ** (គិតដល់ថ្ងៃទី**០១ ខែមេសា ឆ្នាំ២០២១**)
- មានចំណេះដឹងភាសាអង់គ្លេសគ្រប់គ្រាន់ ព្រោះការសិក្សាយកភាសាអង់គ្លេសជាយាន
- មានបទពិសោធន៍ការងារយ៉ាងតិច **០២ឆ្នាំ** ជាបុគ្គលិករដ្ឋដែលធ្វើការពេញម៉ោងតាមស្ថាប័នពាក់ព័ន្ធ (ចំពោះបុគ្គលិកជាប់កិច្ចសន្យាមិនត្រូវបានអនុញ្ញាតទេ)
- មានសុខភាពល្អបរិបូណ៌ទាំងកាយសម្បទា និងសតិបញ្ញា

**២. ថ្នាក់បណ្ឌិត (Doctorate)**

**បេក្ខជនទាំងពីរភេទត្រូវ៖**

- មានសញ្ជាតិខ្មែរ
- បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់(Master Degree) ក្រោមកម្មវិធីអាហារូបករណ៍ JDS

- មានអាយុក្រោម **៤៥ឆ្នាំ** (គិតដល់ថ្ងៃទី០១ ខែមេសា ឆ្នាំ២០២១)

- មានបទពិសោធន៍ការងារយ៉ាងតិច **២ឆ្នាំ** បន្ទាប់ពីបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ក្រោមកម្មវិធីអាហារូបករណ៍ JDS

- ជាបុគ្គលិករដ្ឋដែលធ្វើការពេញម៉ោងតាមស្ថាប័នពាក់ព័ន្ធដូចមានកំណត់ក្នុង Framework of JDS 2019

- មានសុខភាពល្អបរិបូណ៌ទាំងកាយសម្បទា និងសតិបញ្ញា

**II - មុខជំនាញទៅសិក្សា (សម្រាប់ទាំងពីរកម្រិត)**

1. Infrastructure Development
2. Private Sector Development
3. Improvement of Education Quality
4. Agriculture and Rural Development
5. Improvement of Urban Living Environment
6. Improvement of Healthcare and Social Security System
7. Improvement of Administrative Functions
8. Legal and Judicial Development
9. Building of International Relations

**III - កាលបរិច្ឆេទ និងកន្លែងទទួលពាក្យ**

បេក្ខជនដែលមានបំណងចូលរួមក្នុងកម្មវិធីអាហារូបករណ៍នេះ សូមទាក់ទងរកពាក្យសុំអាហារូបករណ៍ និងបំពេញសំណុំឯកសារផ្សេងៗ ចាប់ពីថ្ងៃផ្សាយដំណឹងនេះរហូតដល់ **ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ (ត្រឹមម៉ោង ៣:០០ រសៀល)** នៅការិយាល័យ JICE-JDS ដែលមានអាសយដ្ឋាន៖ **ជាន់ទី៣ អគារ AURA Condominium លេខ ៨៧ វិថី ព្រះត្រសក់ផ្អែម(៦៣) សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ។**

សេចក្តីណែនាំអំពីការដាក់ពាក្យ និង ពាក្យសុំអាហារូបករណ៍មានចែកជូននៅការិយាល័យ JICE-JDS ឬអាចទាញយកបានតាមគេហទំព័រដែលមានអាសយដ្ឋាន៖ **http://jds-scholarship.org/** (លេខសំងាត់ផ្តល់ជូនតាមរយៈគេហទំព័រJDS)។

- បេក្ខជនត្រូវមានប័ណ្ណសំគាល់មន្ត្រីរាជការស៊ីវិលឬលិខិតបញ្ជាក់ពីក្រសួងសាមី

- បេក្ខជនត្រូវដាក់ពាក្យសុំទៅសិក្សាតាមមុខជំនាញដែលពាក់ព័ន្ធនឹងក្រសួងសាមីដូចមានបញ្ជាក់ជូនក្នុងឯកសារភ្ជាប់ជូន( Framework and List of Target Organization ) ។

- បេក្ខជនត្រូវឆ្លងកាត់ការពិនិត្យជ្រើសរើសលើសំណុំលិខិត និងធ្វើសម្ភាសន៍

**IV- វីដេអូពន្យល់ណែនាំអំពីអាហារូបករណ៍ JDS**

បេក្ខជនអាចចូលមើលវីដេអូពន្យល់ណែនាំអំពីអាហារូបករណ៍នៅលើគេហទំព័រJDS (សូមវាយបញ្ចូលលេខសំងាត់ដូចខាងលើដើម្បីមើលវីដេអូ)

[ វីដេអូស្ដីអំពី ]
- សេចក្ដីណែនាំអំពីការដាក់ពាក្យ ( Application Guide )
- របៀបរៀបចំឯកសារ ( How to prepare the applicaiton documents )
- របៀបសរសេរផែនការស្រាវជ្រាវ ( How to write research plan )
- គន្លឹះនៃការជ្រើសរើស ( Tips for the selection )

សម្រាប់ព័ត៌មានបន្ថែម បេក្ខជនអាចទាក់ទងសួរនៅការិយាល័យ JICE-JDS តាមអាសយដ្ឋានខាងលើ ឬតាមរយៈទូរស័ព្ទលេខ៖ 012 681 611/ 023 217 944, email: jds.cambodia1@jice.org ឬនៅការិយាល័យអាហារូបករណ៍ និងកម្មសិក្សា នៃនាយកដ្ឋានទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍ អគារលេខ ២៣ ផ្លូវ៣៦០ ខាងកើតស្ថានីយទូរទស្សន៍អប្សរាប្រហែល ៥០ម៉ែត្រ។

ថ្ងៃ សុក្រ ១០ កើត ៨ ខែ ភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០

**ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
**រដ្ឋលេខាធិការ**

យក់ ឌិយ

**ចម្លងជូន៖**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងមុខងារសាធារណៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ស្ថានទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា
- ការិយាល័យ JICE-JDS នៅភ្នំពេញ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- គ្រប់សាលារាជធានី-ខេត្ត
- គ្រប់មន្ទីរចំណុះឲ្យសាលារាជធានី-ខេត្ត
  "ដើម្បីជួយផ្សព្វផ្សាយនិងឧទ្ទេសនាមបេក្ខជន"
- នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
  "ដើម្បីចុះផ្សាយក្នុងគេហទំព័ររបស់ក្រសួង អយក."
- កាលប្បវត្តិ-ឯកសារ នាយកដ្ឋាន ទវអ.